លីកាដូ
LICADHO

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
**LICADHO**
CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

ប្រអប់សំបុត្រលេខ ៤៩៩
ផ្ទះលេខ ១៦, ផ្លូវ ៩៩, សង្កាត់ បឹងត្របែក, ខណ្ឌចំការមន
ក្រុងភ្នំពេញ, កម្ពុជា
ទូរស័ព្ទ: ៨៥៥ ២៣ ៣៦០ ៩៦៥/៣៦៤ ៩០១
ទូរសារ: ៨៥៥ ៣៦០ ៩៦៥/២១៧ ៦២៦ ឬ + ១ ៨១៥ ៥៥០ ៤៤៧៤
អ៊ីម៉ែល: contact@licadho.org
វិបសាយ: http://www.licadho.org/

ថ្ងៃ ទី៧ ខែមិនា ឆ្នាំ ២០០៨

# សេចក្តីប្រកាសព័ត៌មាន
# ទិវានារីអន្តរជាតិ ៨ មិនា

*នាងខ្ញុំឈ្មោះ លីណា រស់នៅក្នុងពន្ធនាគារជាមួយម៉ាលីដែលជាកូនស្រីម្នាក់ ក្នុងបន្ទប់មួយរួមជាមួយនារីទណ្ឌិតម្ភៃប្រាំនាក់ផ្សេងទៀត ។ នាងខ្ញុំមិនមានជំរើសណាផ្សេងឡើយ ហេតុនេះត្រូវតែនាំកូនស្រីឱ្យមករស់នៅក្នុងពន្ធនាគារជាមួយ ។ ម៉ាលី នាងមានវ័យក្មេងខ្ចីណាស់នាពេលនោះ ។ ប្តីនាងខ្ញុំបានស្លាប់បាត់បង់ជីវិតចោលទៅ ហើយនាងខ្ញុំមិនមានញាតិសន្តានណារស់នៅក្បែរ ដែលអាចពឹងពាក់សុំឱ្យជួយមើលថែរក្សាម៉ាលីបានឡើយ ។*

*រៀងរាល់ថ្ងៃនៅក្នុងពន្ធនាគារ ខ្ញុំពុះពារចិញ្ចឹមម៉ាលី ថ្វីត្បិតបើខ្ញុំត្រូវមានមាត់មួយផ្សេងទៀតត្រូវការចំណីអាហារក៏ដោយ ក៏ខ្ញុំមិនបានទទួលរបបអាហារបន្ថែមណាទៀតឡើយ ។ ខ្ញុំត្រូវតែចែករំលែកអាហារដែលខ្ញុំបានទទួលដើម្បីចិញ្ចឹមម៉ាលី ។ យើងទទួលទានទឹកមិនស្អាត មានពណ៌ខ្មៅ និងធ្វើឱ្យខ្ញុំឈឺ ។ ម៉ាលី តែងតែឈឺធ្ងន់ធ្ងរដែលបណ្តាលមកពីញ៉ាំទឹកកខ្វក់នេះដែរ ។ ប្រសិនបើលោក-អ្នកមិនមានលុយទិញធ្យូង ដើម្បីដាំទឹកពិសា ឬលុយកាក់ទិញទឹកស្អាតពិសាទេនោះ លោក-អ្នកត្រូវតែទទួលទានទឹកមិនស្អាតនោះ ។*

*រឿងដែលអាក្រក់កើតឡើងចំពោះម៉ាលីនោះគឺ នាងរស់នៅក្នុងពន្ធនាគារ ដែលត្រូវគេចាត់ទុកជាអ្នកទោសម្នាក់ដែរ ។ នាងតែងតែត្រូវបានគេចាក់សោរបង្ខាំង មិនមានសេរីភាព ។ នាងមិនត្រូវបានអនុញ្ញាតឱ្យលេងកំសាន្តដូចកុមារទូទៅឡើយ ។*

*ម៉ាលី នាងនៅវ័យក្មេងខ្ចីណាស់សំរាប់ការយល់ដឹងពីអ្វីៗ ដែលកំពុងកើតឡើង ឬយល់អត្ថន័យពីជីវភាពរស់នៅក្នុងពន្ធនាគារ ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ខ្ញុំតែងតែមានការសោកស្តាយដោយយល់ថា កូនស្រីខ្ញុំបានធំលូតលាស់ក្នុងពន្ធនាគារដែលមានស្ថានភាពដ៏អាក្រក់បែបនេះ ។*

លីណា ជានារីទណ្ឌិតម្នាក់ក្នុងចំណោមទណ្ឌិតនារីចំនួនជាង ៦៤០នាក់ ហើយក៏ជាទណ្ឌិតនារីនៃម្តាយម្នាក់ក្នុងចំណោមម្តាយ ៤៣នាក់ ដែលមានកូនកំពុងរស់នៅជាមួយពួកគេនៅក្នុងពន្ធនាគារ រីឯកូនស្រីរបស់នាងក៏ជាកុមារីម្នាក់ក្នុងចំណោមកុមារចំនួន ៥០នាក់ ផ្សេងទៀតផងដែរ ។ រឿងរ៉ាវរបស់ពួកគេ បានរៀបរាប់ក្នុងរបាយការណ៍ លីកាដូ

លីកាដូ
LICADHO

**សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

ប្រអប់សំបុត្រលេខ ៤៩៩
ផ្ទះលេខ ១៦, ផ្លូវ ៩៩, សង្កាត់ បឹងត្របែក, ខណ្ឌចំការមន
ក្រុងភ្នំពេញ, កម្ពុជា
ទូរស័ព្ទ: ៨៥៥ ២៣ ៣៦០ ៩៦៥/៣៦៤ ៩០១
ទូរសារ: ៨៥៥ ៣៦០ ៩៦៥/២១៧ ៦២៦ ឬ + ១ ៨១៥ ៥៥០ ៤៤៧៤
អ៊ីម៉ែល: **contact@licadho.org**
វិបសាយ: **http://www.licadho.org/**

ដែលមានចំណងជើងថា "**ស្ថានភាពពន្ធនាគារ កម្ពុជា ឆ្នាំ២០០៧:** *ជាសាច់រឿងអំពី* ***ម្តាយ និង កូនស្រីម្នាក់*** " ដែលនឹងត្រូវចែកចាយក្នុងឱកាសប្រារព្ធទិវានារីអន្តរជាតិ ៨ មិនា ឆ្នាំ២០០៨ ។"

របាយការណ៍នេះមានបំណងនឹងជំរាបជូនជាលើកដំបូង អំពីជីវភាពរស់នៅក្នុងពន្ធនាគាររបស់នារីម្នាក់ ជាម្តាយដែលបាននាំកូនស្រីឱ្យមករស់នៅក្នុងពន្ធនាគារជាមួយ ។ ច្បាប់កម្ពុជាអនុញ្ញាតឱ្យក្មេងអាយុក្រោមប្រាំមួយឆ្នាំអាចមករស់នៅជាមួយឪពុកម្តាយក្នុងពន្ធនាគារបាន ប្រសិនបើពួកគេគ្មានជំរើសណាផ្សេងទៀត ក្នុងការទទួលបានការថែរក្សាពីខាងក្រៅទេនោះ ។ បញ្ហាចំបងសំខាន់នោះ គឺកុមារទាំងនោះមិនបានទទួលម្ហូបអាហារគ្រប់គ្រាន់ទេ ( មិនមានរបបអាហារបន្ថែមណាសំរាប់ម្តាយដែលមានកូនរស់នៅជាមួយទេ ហេតុនេះពួកគេត្រូវចែករំលែកម្ហូបអាហារពីរបបរបស់គេ) ។ នៅទីនោះមិនអាចឱ្យកុមារទទួលការអប់រំគ្រប់គ្រាន់ឡើយ ហើយខណៈដែលពួកគេរស់នៅជាមួយម្តាយក្នុងពន្ធនាគារ កុមារទាំងនោះត្រូវបានថែទាំបែបជាអ្នកទោសទៅវិញ ។ លោកស្រីវិជ្ជបណ្ឌិត ពុង ឈីវ កេក ប្រធានអង្គការលីកាដូ បានមានប្រសាសន៍ថា "ទិវានារីអន្តរជាតិ គឺជាថ្ងៃសម្តែងនូវការអបអរសាទរដល់នារីគ្រប់រូប រួមទាំងការលើកស្ទួយសិទ្ធិនារីផងដែរ ។ ជាពិសេសក្នុងថ្ងៃនេះ យើងសូមសម្តែងនូវការនឹករឭកចំពោះនារីទាំងអស់ ដែលកំពុងរស់នៅក្នុងពន្ធនាគារជាមួយកូនប្រុសស្រីរបស់គេ ជាសមាជិកងាយរងគ្រោះពីសង្គម និងមិនត្រូវទទួលរងការបន្ទាបបន្ថោក ឬបំភ្លេចចោលឡើយ " ។

ដើម្បីរំឭកទិវានារីអន្តរជាតិនេះ និង ដើម្បីផ្តោតការយកចិត្តទុកដាក់លើស្ថានភាពនារីក្នុងពន្ធនាគារនៅកម្ពុជា អង្គការ លីកាដូ នឹងរៀបចំពិធីចែកចាយម្ហូបអាហារ និងសម្ភារៈដល់នារីជាទណ្ឌិត ពិរុទ្ធជន និងកុមារទាំងឡាយដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារ និងនារីមន្ត្រីពន្ធនាគារនៅពន្ធនាគារចំនួន ១៨កន្លែង ទូទាំងប្រទេសកម្ពុជា ។

**<u>ព័ត៌មានបន្ថែម សូមមេត្តាទាក់ទង :</u>**

- **លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការ លីកាដូ**

  **ទូរស័ព្ទលេខ : (៨៥៥)១២ ៩៤០ ៦៤៥**